វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៩៦ អនក្រ.បក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០០

# អនុក្រឹត្យ

## ស្តីពីការ

## រៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន

## នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ សន/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០០/២១៣ ចុះថ្ងៃទី ២៩ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ/បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- តាមសំណើរបស់ ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់បេសកកម្មមុខងារ ភារកិច្ច និងការរៀបចំអង្គភាពនានា របស់អគ្គលេធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

## ជំពូកទី ២

## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា ២.-**

ក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានអគ្គលេខាធិការដ្ឋានមួយ ជាអង្គភាពប្រតិបត្តិ ដែលត្រូវដឹកនាំ និង គ្រប់គ្រងដោយអគ្គលេខាធិការមួយរូប ។

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានបេសកកម្មដាក់អោយដំណើរការកម្មវិធីការងារដីធ្លី តាមការណែនាំ និងការចង្អុលទិសរបស់ប្រធាន ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។ ក្នុងបេសកកម្មនេះ អគ្គលេខាធិការដ្ឋានមានភារកិច្ច ជាអាទិ៍ :

១- រៀបចំគោលនយោបាយដីធ្លីទូលំទូលាយ ។

២- ធ្វើវិភាគនយោបាយ និងទំនាក់ទំនងពិគ្រោះយោបល់ដើម្បីរកការឯកភាព និង ការគាំទ្រពីគ្រប់មជ្ឈដ្ឋាន ប្រជាពលរដ្ឋលើគោលនយោបាយដីធ្លី ។

៣- លើកសំណើគោលនយោបាយដីធ្លី ទស្សនទាន ផែនការកម្ម ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លីដើម្បីពិនិត្យ និងសំរេច ។

៤- លើកគំរោងការងារដីធ្លី គ្រប់ផ្នែក ជាពិសេសផ្នែក គ្រប់គ្រងដីធ្លី រៀបចំដែនដី និងបែងចែកដីធ្លី ដាក់អោយ ដំណើការអនុវត្តន៍ ធ្វើការសំរបសំរួល និងវាយតំលៃការងារ ។

៥- យកចិត្តទុកដាក់លើការអនុវត្តន៍គោលនយោបាយ ប្រើប្រាស់ដីឱ្យបានសមស្រប និងមានសមធមិ

៦- ជំរុញការចុះបញ្ជីដីធ្លីជាប្រព័ន្ធទូទាំងប្រទេស ។

៧- ជំរុញការគ្រប់គ្រងផ្នែករដ្ឋបាលសុរិយាដីលើអចលនវត្ថុ ជាទ្រព្យសម្បត្តិរបស់រដ្ឋឱ្យមានប្រសិទ្ធភាព

៨- សិក្សា រៀបចំគោលនយោបាយពន្ធដារលើដីធ្លី ដើម្បីជំរុញឱ្យមានការអភិវឌ្ឍន៍ និងសណ្តាប់ធ្នាប់

៩- ធ្វើការទំនាក់ទំនងដើម្បីជំរុញឱ្យមានទំនើបកម្ម ឧបករណ៍ និងធនធានមនុស្សប្រកបដោយឯកទេសគ្រប់គ្រាន់ដើម្បី បំពេញការងារ ។

១០- ជំរុញការកសាងច្បាប់ បទប្បញ្ញត្តិ បទបញ្ជា បទដ្ឋានឱ្យបានគ្រប់គ្រាន់ ដើម្បីដំណើរការការងារដីធ្លី ។

១១- លើកវិធានការជាយុទ្ធសាស្រ្ត ដើម្បីទប់ស្កាត់ និងកាត់បន្ថយទំនាស់ដីធ្លី ។

១២- លើកផែនការបណ្តុះបណ្តាល និងផ្សព្វផ្សាយ ដល់ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋទូទៅ ជាពិសេសអំពីការងារដីធ្លី ។

១៣- ជំរុញតាមដាន វាយតំលៃលើគំរោងការងារដែលបានអនុវត្ត ព្រមទាំងធ្វើរបាយការណ៍ទៀតទាត់ជូនក្រុមប្រឹក្សា គោលនយោបាយដីធ្លីអំពីលទ្ធផលការងារ ។

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវធ្វើការប្រជុំការងារយ៉ាងតិចមួយដង ក្នុងមួយខែ តាមការអញ្ជើញ និងការណែនាំរបស់អគ្គលេខាធិការ ។

**មាត្រា ៥.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីបំពេញការងាររបស់ខ្លួន ។

**មាត្រា ៦.-**

អគ្គលេខាធិការ មានសិទ្ធិលើកសំណើជូន ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដើម្បីពិនិត្យ និងសំរេច លើសេចក្តីសំរេចប្រកាសតែងតាំង ឬដកចេញពីតំណែង នូវមន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានរចនាសម្ព័ន្ធដូចតទៅ :

១- ក្រុមការងារនយោបាយ និងគតិយុត្តិ

២- ក្រុមការងារបច្ចេកទេស

៣- ក្រុមការងារពង្រឹងស្ថាប័ន

៤- ក្រុមការងាររដ្ឋបាល

ក្រុមការងារនីមួយៗ ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាន មួយរូប និងអនុប្រធានជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៨.-**

ការបែងចែកលំអិតនៃ ភារកិច្ចរបស់បុគ្គលិក និងមន្ត្រីរាជការដែលបំរើការងារនៅក្នុងអគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយប្រកាស របស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

**មាត្រា ៩.-**

ក្រុមការងារនយោបាយ និងគតិយុត្តិ មានភារកិច្ច :

- រៀបចំគោលនយោបាយដីធ្លី ទូលំទូលាយ

- ធ្វើវិភាគនយោបាយ និង ទំនាក់ទំនងពិគ្រោះយោបល់ ដើម្បីរកការឯកភាព និងការគាំទ្រពីគ្រប់មជ្ឈដ្ឋាន ប្រជាពលរដ្ឋ ដែលពាក់ព័ន្ធ និងបញ្ហាដីធ្លី លើគោលនយោបាយដីធ្លី
- លើកសំណើគោលនយោបាយកំណែទំរង់ដីធ្លី ទស្សនទាន ផែនការកម្ម ជូនក្រុមប្រឹក្សាកំណែទំរង់ដីធ្លី ដើម្បីពិនិត្យ និងសំរេច
- យកចិត្តទុកដាក់លើការអនុវត្តន៍គោលនយោបាយប្រើប្រាស់ដីធ្លីឱ្យបានសមស្រប និងមានសមធម៌
- សិក្សា រៀបចំគោលនយោបាយពន្ធដារលើដីធ្លី ដើម្បីជំរុញ ឱ្យមានការអភិវឌ្ឍន៍ និងសណ្តាប់ធ្នាប់
- ជំរុញការកសាងច្បាប់ បទប្បញ្ញត្តិ បទបញ្ជា បទដ្ឋាន ឱ្យបានគ្រប់គ្រាន់ដើម្បីដំណើរការការងារដីធ្លី
- លើកវិធានការជាយុទ្ធសាស្ត្រ ដើម្បីទប់ស្កាត់ និងកាត់បន្ថយទំនាស់ដីធ្លី ។

**មាត្រា ១០.-**

ក្រុមការងារបច្ចេកទេស មានភារកិច្ច :

- លើកគំរោងការងារដីធ្លីនៅគ្រប់ផ្នែក ជាពិសេសផ្នែកគ្រប់គ្រងដីធ្លី រៀបចំផែនដី និងបែងចែកដីធ្លីដាក់ឱ្យដំណើរការ អនុវត្តន៍ ធ្វើការសំរបសំរួល និងវាយតំលៃការងារ ។
- ជំរុញការចុះបញ្ជីដីធ្លីជាប្រព័ន្ធ ទូទាំងប្រទេស
- ជំរុញការគ្រប់គ្រងផ្នែករដ្ឋបាលសុរិយាដីលើអចលវត្ថុជាទ្រព្យសម្បត្តិរបស់រដ្ឋឱ្យមានប្រសិទ្ធភាព

**មាត្រា ១១.-**

ក្រុមការងារពង្រឹងស្ថាប័ន មានភារកិច្ច :

- ធ្វើទំនាក់ទំនងដើម្បីជំរុញឱ្យមានទំនើបកម្ម ឧបករណ៍ និងធនធានមនុស្សប្រកបដោយឯកទេសគ្រប់គ្រាន់ ដើម្បីបំពេញការងារ
- លើកផែនការបណ្តុះបណ្តាល និងផ្សព្វផ្សាយ ដល់ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋទូទៅជាពិសេសអំពីការងារដីធ្លី
- ពង្រឹងគណៈកម្មការដោះស្រាយបាតុភាពបញ្ហាទំនាស់ដីធ្លី ។

**មាត្រា ១២.-**

ក្រុមការងាររដ្ឋបាល មានភារកិច្ចៈ

- គ្រប់គ្រងការងាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន
- កសាងគំរោងថវិកាប្រចាំឆ្នាំ និងគ្រប់គ្រងការអនុវត្តន៍ថវិកា
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ

- រៀបចំ និងសំរួលកិច្ចប្រជុំ និងការពិភាក្សារបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- ធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗ របស់អគ្គលេខាធិការដ្ឋាន
- តាមដានវាយតំលៃគំរោងការដីធ្លី ដែលបានអនុវត្ត ព្រមទាំងធ្វើរបាយការណ៍ទៀងទាត់ជូនក្រុមប្រឹក្សា គោលនយោបាយដីធ្លីអំពីលទ្ធផលការងារនេះ ។

**មាត្រា ១៣.-**

អគ្គលេខាធិការដ្ឋានប្រើប្រាស់បុគ្គលិក នៃមុខងារសាធារណៈ ឬ អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ល័ក្ខខ័ណ្ឌនៃលាភការរបស់ភ្នាក់ងារ ជាប់កិច្ចសន្យា និងប្រាក់បំណាច់ ពិសេសសំរាប់បើកជូនភ្នាក់ងារមុខងារ សាធារណៈត្រូវកំណត់ដោយប្រកាស របស់ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី តាមសំណើរបស់អគ្គលេខាធិការ ។

**មាត្រា ១៤.-**

សមាជិក និងបុគ្គលិកទាំងអស់របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លីអាចទទួលបាននូវប្រាក់បំណាច់ផ្សេង ៗ ដែលបានផ្តល់មកពីប្រទេស ឬ អង្គការផ្តល់ជំនួយអន្តរជាតិនានា ។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា ១៥.-**

ការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លីចាប់ពីក្រោមថ្នាក់ប្រធាននាយដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមសំណូមពររបស់អគ្គលេខាធិការនៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

**មាត្រា ១៦.-**

បទប្បញ្ញត្តិ ទាំងឡាយណាដែលផ្ទុយនិងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៧.-**

ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់គ្រងក្រសួងស្ថាប័ន និងសមាជិកទាំងអស់របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងខ្លួន ចាប់ពី ថ្ងៃចុះហត្ថលេខាតទៅ ។